**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Feb-2012, 14:01
CMS/CFO: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:
ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:
ឈ្មោះមន្ត្រីដែលបានពិនិត្យ:
ហត្ថលេខា:

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសារណាបន្ថែមរបស់ នួន ជា ទាក់ទងនឹងសំណើសុំការបញ្ជាក់អំពីប្រភពដើម/ខ្សែសង្វាក់នៃការគ្រប់គ្រងឯកសាររបស់ DC-Cam

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
សុន អរុណ
Michiel PESTMAN
Victor Koppe
អាង ឧត្ដម
Michael G.KARNAVAS
គង់ សំអុន
Anta GUISSÉ
Arthur VERCKEN
Jacques VERGÈS

## I. សេចក្តីផ្តើម

១- នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ មេធាវីការពារក្តីនួន ជា("មេធាវីការពារក្តី") បានដាក់សំណើមួយដែលមានចំណងជើងថា "សារណាបន្ថែម ទាក់ទងនឹងសំណើសុំការបញ្ជាក់អំពីប្រភពដើម/ខ្សែសង្វាក់នៃការគ្រប់គ្រងឯកសាររបស់ DC-Cam"[1] ("សារណារបស់មេធាវីការពារក្តី") ដែលបានជូនដំណឹងដល់គូភាគីជាភាសាខ្មែរនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២។

២- សារណារបស់មេធាវីការពារក្តី បានអះអាង "ទាក់ទងនឹងសំណើសុំការបញ្ជាក់អំពីប្រភពដើម និង ខ្សែសង្វាក់នៃការគ្រប់គ្រងឯកសារ ដែលបានផ្តល់ជូនដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam") ដែលការិយាល័យសហព្រះរាជអាជ្ញាមានចេតនាពឹងផ្អែកទៅលើ នៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី"[2]។ សារណារបស់មេធាវីការពារក្តីនេះ ធ្វើឡើងបន្ទាប់ពីមានសំណើដែលបានធ្វើឡើងដោយមេធាវីការពារក្តី នៅក្នុងអំឡុងពេលនៃការសួរដេញដោលលោក ឆាំង យុ ដើម្បីឲ្យមានការបង្ហាញអំពីខ្សែសង្វាក់នៃការគ្រប់គ្រង និងប្រភពដើមឯកសារ នៅចំពោះមុខអង្គជំនុំជម្រះ ដែលមានប្រភពចេញពីអង្គការរបស់គាត់ គឺ DC-Cam[3]។

៣- ជាក់លាក់ជាងនេះទៀត សារណារបស់មេធាវីការពារក្តីស្នើសុំព័ត៌មាន ដែលមាននៅក្នុងមូលដ្ឋានទិន្នន័យ ចំនួនពីរដូចខាងក្រោម ៖

(ក) "កំណត់សំគាល់អំពីប្រភព/ប្រភពដើម (៣១៧)" - មេធាវីការពារក្តីធ្វើការកត់សំគាល់ថា ក្បួន (manual) របស់ DC-Cam សម្រាប់មូលដ្ឋានទិន្នន័យស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍កម្ពុជា ផ្តល់នូវហ្វៀល (field) "ប្រើដើម្បីកត់ត្រាព័ត៌មានផ្សេងៗអំពីប្រភពនៃវត្ថុនោះ, ម្ចាស់ពីមុន/ម្ចាស់បច្ចុប្បន្ន"[4]។ មេធាវីការពារក្តីអះអាងថា លោក ឆាំង យុ បានផ្តល់សក្ខីកម្មថា ហ្វៀលនេះ គឺជា "ទីកន្លែងដែលព័ត៌មានអំពីប្រភពដើម/ខ្សែសង្វាក់នៃការគ្រប់គ្រងឯកសារ ត្រូវបានគេកត់ត្រាទុកចំពោះឯកសារ ទាំងឡាយដែលទទួលបានដោយ DC-Cam[5]។

---

[1] **E1/39.1/1**, សារណាបន្ថែមទាក់ទងនឹងសំណើសុំការបញ្ជាក់អំពីប្រភពដើម/ខ្សែសង្វាក់នៃការគ្រប់គ្រងឯកសាររបស់ DC-Cam, ៩ កុម្ភៈ ២០១២។

[2] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី១។

[3] **E1/39.1**, ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ៦ កុម្ភៈ ២០១២, ទំព័រទី៨០:១ - ៨១:១។

[4] E1/39.1/1, ត្រង់កថាខណ្ឌទី២។

[5] *ដដែលដូចខាងលើ*។

(ខ) "ការកត់សំគាល់ទាក់ទងនឹងច្បាប់ចម្លងនៃឯកសារ ដែលគេបានធ្វើឯកសារគំរូ/កាតាឡុក (៣១៦)"។ មេធាវីការពារក្តីអះអាងថា លោក ឆាំង យុ បានផ្តល់សក្ខីកម្មថា ការស្រាវជ្រាវនេះ "មានផ្ទុកនូវព័ត៌មានទាក់ទងនឹងសំណួរថាតើ DC-Cam កាន់កាប់ច្បាប់ដើមនៃឯកសារដែរឬទេ ឬក៏គ្រាន់តែជាច្បាប់ចម្លង ក្នុងចំណោមព័ត៌មានផ្សេងៗទៀត"[6]។

៤- នៅពេលធ្វើសំណើសុំច្បាប់ដើមដោយផ្ទាល់មាត់ អំពីព័ត៌មានដែលមាននៅក្នុងហៀល ៣១៦ និង៣១៧ មេធាវីការពារក្តីបានអះអាងដោយសន្មតពីសំណើរបស់ខ្លួនលើព័ត៌មាន"ដ៏សំខាន់បំផុត" និង"ស្ថានភាពដែលមិនធ្លាប់មានពីមុនមកដែលថា អង្គការឯកជនមួយត្រូវបានក្លាយជាឧបករណ៍នៅក្នុងការប្រមូលភ័ស្តុតាងនៅក្នុងរឿងព្រហ្មទណ្ឌ"[7]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខ្លួននឹងឆ្លើយតបទៅនឹងសំណើមេធាវីការពារក្តីក្នុងពេលណាមួយសមស្រប[8]។

៥- នៅក្នុងសារណារបស់មេធាវីការពារក្តី, មេធាវីការពារក្តីស្នើឱ្យបង្ហាញព័ត៌មាននៅក្នុងហៀលទាំងពីរដោយឈរលើទឡ្ហីករណ៍ចំនួនពីរ។ ទីមួយ, ខ្លួនអះអាងថា ព័ត៌មានទាំងនោះមានការពាក់ព័ន្ធយ៉ាងខ្លាំងដោយហេតុថាវានឹង "ផ្តល់ឱ្យភាគីនានានូវទិដ្ឋភាពយ៉ាងទូលំទូលាយ អំពីព័ត៌មានដែលមានទាំងអស់ (នៅ DC-Cam) ទាក់ទងនឹងប្រភពដើម និងខ្សែសង្វាក់នៃការគ្រប់គ្រងឯកសារនិមួយៗរបស់ DC-Cam ដែល កសព មានចេតនាពឹងផ្អែក"[9]។ ទីពីរ, មេធាវីការពារក្តីអះអាងថាព័ត៌មានទាំងនេះនឹងបានជាជំនួយនៅក្នុង "ការឆ្លើយថាភូតឯកសារសក្តានុពលនានា [របស់ DC-Cam] ដោយសារវានឹងផ្តល់ឱ្យភាគី នូវព័ត៌មានដែលពាក់ព័ន្ធនឹង (ទីកន្លែង និង/ឬ នត្ថិភាព ឬ អត្ថិភាព) នៃឯកសារដើម (ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ)"[10]។

៦- សហព្រះរាជអាជ្ញាសូមធ្វើការឆ្លើយតបទៅនឹងសារណារបស់មេធាវីការពារក្តីនេះ ដោយចង្អុលបង្ហាញថា ព័ត៌មានដែលបានស្នើឡើង គឺមិនចាំបាច់ឱ្យមានការវាយតម្លៃរបស់អង្គជំនុំជម្រះអំពីភាពអាចទទួលយកបាននៃភ័ស្តុតាងឯកសារទេ។ បទដ្ឋាននានាដែលបានស្វែងរកដោយមេធាវីការពារក្តីមកអនុវត្តមេធាវីការពារក្តី គឺមានលក្ខណៈតឹងរ៉ឹងជាងអ្វីដែលបានសម្រេចរួចហើយដោយអង្គជំនុំជម្រះ។ ដើម្បី

---

[6] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី៣។

[7] **E39.1,** at pp. 80:16 – 81:1.

[8] *ដដែលដូចខាងលើ,* ត្រង់ទំព័រទី៨៩:២១-២២។

[9] **E1/39.1/1**, ត្រង់កថាខណ្ឌទី៤។

[10] *ដដែលដូចខាងលើ*។

អនុវត្តឲ្យបានត្រឹមត្រូវទៅតាមបទដ្ឋាន ក.ស.ព បានដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះ នូវព័ត៌មានដ៏សំបូរបែប អំពីការកំណត់យថាភូតនៃឯកសារដែលខ្លួនស្វែងរកដើម្បីឲ្យទទួលយក តាមរយៈការដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខអក្សរដ៏វែង និងភស្តុតាង ជាតួយ៉ាងនៅពេលសវនាការផ្ទាល់មាត់ក្នុងអម្លុពេលនៃការជំនុំជម្រះ។

## II. ប្រវត្តិនីតិវិធី

៧- ក្នុងរយៈពេលដប់ខែកន្លងមកនេះ សហព្រះរាជអាជ្ញាបានផ្ដល់នូវឈុតបញ្ជីឯកសារមួយចំនួន ជូនដល់អង្គជំនុំជម្រះ និងភាគីដទៃទៀត។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសាររបស់ខ្លួនដែលសហព្រះរាជអាជ្ញាមានចេតនាពឹងផ្អែកនៅពេលសវនាការ[11]។ បន្ទាប់ពីមានការណែនាំ របស់អង្គជំនុំជម្រះឲ្យគូភាគី កំណត់អត្តសញ្ញាណឯកសារ និងវត្ថុតាងដែលខ្លួនពិចារណាថាពាក់ព័ន្ធនឹងការជំនុំជម្រះដំណាក់កាលដំបូង[12], សហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសារដំណាក់កាលដំបូងរបស់ខ្លួន នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១[13]។ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់សេចក្ដីជូនដំណឹងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អំពីឯកសារដែលត្រូវដាក់របស់ខ្លួនដែលជាប់ពាក់ព័ន្ធទៅនឹងសាក្សី និងអ្នកជំនាញដែលអាចនឹងត្រូវកោះហៅ នៅក្នុងអម្លុងពេលបីសប្ដាហ៍ដំបូងនៃសវនាការ និងបានភ្ជាប់នូវបញ្ជីឯកសារផងដែរ[14]។ មេធាវីការពារក្ដីបានដាក់ការជំទាស់ទូទៅទៅនឹងបញ្ជីឯកសារនេះ[15]។ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងការជំទាស់របស់មេធាវីការពារក្ដីតាមរយៈការដាក់ចម្លើយតបរួមរបស់ខ្លួន ទៅនឹងការជំទាស់ទៅនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់វគ្គទីមួយនៃការជំនុំជម្រះដំបូង នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១១[16]។ បន្ទាប់មកនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់សេចក្ដីសន្និដ្ឋាន អនុលោមតាមវិធាន៩២

---

[11] **E9/31**, បញ្ជីឯកសារសម្រាប់សវនាការរបស់សហព្រះរាជអាជ្ញា អនលោមតាមវិធាន៨០(៣), ១៩ មេសា ២០១១។

[12] **E1/4.1**, ប្រតិចារិកនៃសវនាការបឋមជាសាធារណៈ, ២៧ មិថុនា ២០១១, ទំព័រទី២៥។

[13] **E109/4**, ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំឯកសារដែលពាក់ព័ន្ធនឹងសវនាការនៅដំណាក់កាលដំបូង, ២២ កក្កដា ២០១១, E109/4.1-4.20។

[14] **E131/1/4**, សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីឯកសារដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរបស់ខ្លួនដែលជាប់ពាក់ព័ន្ធទៅនឹងសាក្សី និងអ្នកជំនាញដែលអាចនឹងត្រូវកោះហៅនៅក្នុងអម្លុងពេលបីសប្ដាហ៍ដំបូងនៃសវនាការ ដោយភ្ជាប់ទៅជាមួយនូវឧបសម្ព័ន្ធ ក សម្ងាត់, ១ វិច្ឆិកា ២០១១។ **E131/1/4.1**, ឧបសម្ព័ន្ធ ក, ១ វិច្ឆិកា ២០១១។

[15] **E131/1/9**, ការជំទាស់ ការកត់សំគាល់ និងការជូនដំណឹងរបស់ នួន ជា ទាក់ទងនឹងឯកសារដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ១៤ វិច្ឆិកា ២០១១, កថាខណ្ឌទី១៧-១៩។

[16] **E131/1/19**, ចម្លើយតបរួមទៅនឹងការជំទាស់ទៅនឹងបញ្ជីឯកសារសម្រាប់សវនាការវគ្គដំបូងរបស់សហព្រះរាជអាជ្ញា, ១ ធ្នូ ២០១១។

របស់ខ្លួន ដោយគូសបញ្ជាក់អំពីសញ្ញាសំគាល់នៃភាពអាចជឿទុកចិត្តបានពាក់ព័ន្ធនឹងឯកសារនិមួយៗ នៅលើបញ្ជីឯកសារចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១[17]។

៨- នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ មេធាវីការពារក្តីបានដាក់ការជំទាស់របស់ខ្លួនទៅនឹងឯកសារនានា អនុលោមតាមវិធាន៩២ ដោយបញ្ជាក់អំពីជំហររបស់ខ្លួន ដូចការជំទាស់ជាទូទៅលើកមុនដែរ ទាក់ទងនឹងការទទួលយកភ័ស្តុតាងឯកសារនៅពេលជំនុំជម្រះ[18]។ មេធាវីការពារក្តីក៏បានស្នើផងដែរឲ្យកោះហៅ លោក ឆាំង យុ ជានាយក DC-Cam មកធ្វើជាសាក្សីនៅក្នុងសវនាការ[19]។

៩- អង្គជំនុំជម្រះសាលាដំបូងបានធ្វើសវនាការផ្ទាល់មាត់ ស្តីពីភាពអាចទទួលយកបាននៃភស្តុតាងជាឯកសារ នៅចន្លោះពេលពីថ្ងៃទី១៦ ដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ ដោយចំណាយពេលចំនួនបីថ្ងៃ សំរាប់ការពិភាក្សាលើការជំទាស់ផ្សេងៗទៅនឹងឯកសារចំនួនប្រាំប្រភេទ[20]។

១០- សាក្សីចំនួនពីរនាក់ ក្នុងចំណោមសាក្សីជាច្រើនផ្សេងទៀត ត្រូវបានកោះហៅ និងផ្តល់សក្ខីកម្ម អំពីការអនុវត្ត ក្នុងការប្រមូលចងក្រង និងការរៀបចំបណ្ណសាររបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)។ លោក វ៉ាន់ថាន់ ដាភ៉ៅ ជានាយករងនៃ DC-Cam បានផ្តល់សក្ខីកម្មអស់រយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២[21]។ លោក ឆាំង យុ ជានាយកនៃ DC-Cam ក៏បានផ្តល់សក្ខីកម្មអស់រយៈពេលបីថ្ងៃផងដែរ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១២[22]។ សាក្សីទាំងពីររូបនេះត្រូវបានធ្វើការសាកសួរដោយគ្រប់ភាគីទាំងអស់។

---

[17] **E158**, សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន៩២ ទាក់ទិននឹងសញ្ញាបង្ហាញអំពីភាពអាចជឿទុកចិត្តបានចំពោះឯកសារចំនួន៩៧៨ ដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចកោះហៅសម្រាប់សវនាការបីសប្តាហ៍ដំបូង, ២៣ ធ្នូ ២០១១។

[18] **E131/1/12**, ការជំទាស់ទៅនឹងឯកសារ និងសារណាបន្ថែមរបស់ នួន ជា អនុលោមតាមវិធាន៩២, ៥ មករា ២០១២។

[19] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី៣។

[20] ឯកសារលេខ **E159**, អនុស្សរណៈរបស់អង្គជំនុំជម្រះ ស្តីពី ការកំណត់កាលបរិច្ឆេទសំរាប់ការធ្វើសវនាការផ្ទាល់មាត់ស្តីពីឯកសារនានា ចាប់ពីថ្ងៃទី១៦-១៩ ខែមករា ឆ្នាំ២០១២, ចុះថ្ងៃទី១១ មករា ២០១២។

[21] ឯកសារលេខ **E1/31.1**, ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី, ចុះថ្ងៃទី២៣ មករា ២០១២។ ឯកសារលេខ **E1/32.1**, ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី, ចុះថ្ងៃទី២៤ មករា ២០១២។ ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី។ ឯកសារលេខ **E1/33.1**, ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី, ចុះថ្ងៃទី២៦ មករា ២០១២។

[22] ឯកសារលេខ **E1/37.1**, ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី, ចុះថ្ងៃទី១ កុម្ភៈ ២០១២។ ឯកសារលេខ E1/38.1, ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី, ចុះថ្ងៃទី២ កុម្ភៈ ២០១២។ **E1/39.1**, ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី, ចុះថ្ងៃទី ៦ មករា ២០១២។

## III. ច្បាប់ជាធរមាន

១១- នៅក្នុងពេលថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បំភ្លឺអំពីបទដ្ឋានដែលត្រូវអនុវត្តនៅពេលធ្វើការវាយតម្លៃអំពីភាពអាចទទួលយកបាននៃភស្តុតាងជាឯកសារនានា នៅក្នុង អវតក។ ការសំរេចរបស់អង្គជំនុំជម្រះនេះត្រូវបានដាក់ជូនទៅភាគីនានាក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ តាមរយៈអនុស្សរណៈរបស់ខ្លួន ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ ("អនុស្សរណៈ")។ កថាខណ្ឌដែលត្រូវអនុវត្តនៅក្នុងអនុស្សរណៈ ដែលមានការជាប់ទាក់ទងខ្លាំងជាងគេទៅនឹងចម្លើយតបចំពោះមុខនេះ គឺមានដូចខាងក្រោម៖

> *"វិធាន៨៧(៣)(គ)នៃវិធានផ្ទៃក្នុង [] តម្រូវឱ្យឯកសារទាំងឡាយដែលមានបំណងដាក់ជូនអង្គជំនុំជម្រះ ត្រូវតែបំពេញឱ្យបានទៅតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋានស្តីពីភាពជាប់ពាក់ព័ន្ធ ភាពអាចឱ្យជឿទុកចិត្តបាន និងយថាភាពដោយគ្រាន់ឃើញមួយក្រឡេកផ្នែកដំបូង។ ឧទាហរណ៍ បើសិនជា ឯកសារណាមួយដែលបង្ហាញឱ្យឃើញថា គ្មានការក្លែងបន្លំ ឬមិនមែនមិនតំណាងឱ្យឯកសារច្បាប់ដើមនោះ អង្គជំនុំជម្រះត្រូវតែចាត់ទុកថា ឯកសារត្រូវបានដាក់នៅចំពោះមុខខ្លួន។ ការជំទាស់ផ្សេងៗប្រភេទនេះត្រូវតែបានលើកឡើងនៅពេលដែលត្រូវបានស្នើសុំឱ្យដាក់ឯកសារណាមួយ ឬ ភស្តុតាងផ្សេងទៀតនៅចំពោះមុខអង្គជំនុំជម្រះ។ ការដាក់សារណាណាមួយបន្ថែមទៀត ដូចជា ស្តីពីភាពអាចជឿទុកចិត្តបាននៃឯកសារ ត្រូវបញ្ជូនទៅឱ្យអង្គជំនុំជម្រះជាជំនួស ដើម្បីធ្វើការថ្លឹងថ្លែងផ្តល់ការយល់ព្រមស្តីពីទម្ងន់របស់ភស្តុតាងនោះ"[23] ។*

១២- អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញដែរថា នៅពេលដែលគ្មានលក្ខខណ្ឌតម្រូវទាក់ទងនឹងនីតិវិធីនៅចំពោះមុខ អវតក ក្នុងការកោះហៅសាក្សីដែលមានការដឹងឮដោយផ្ទាល់ ដើម្បីបញ្ជាក់ពីយថាភាពនៃឯកសារ ដែលមាននៅក្នុងសំណុំរឿងទេនោះ ការផ្តល់សក្ខីកម្ម ដូចជា អំពីខ្សែសង្វាក់ក្នុងការថែរក្សាគ្រប់គ្រងឯកសារ និងប្រភពនៃឯកសារ នឹងជួយដល់អង្គជំនុំជម្រះនៅក្នុងការវាយតម្លៃអំពីទម្ងន់(ជាភស្តុតាង)ដែលត្រូវផ្តល់ឱ្យ ទៅលើឯកសារដោយឡែកណាមួយចំនួន"[24]។

១៣- ការរកឃើញរបស់អង្គជំនុំជម្រះ គឺជាការឆ្លុះបញ្ចាំងឱ្យឃើញពីជំហរតាំងពីយូរមកហើយរបស់សហព្រះរាជអាជ្ញា ដែលថា "ភស្តុតាងដែលត្រូវទទួលយកនៅ អវតក ត្រូវតែបំពេញឱ្យបានតាម

[23] ឯកសារលេខ **E162**, អនុស្សរណៈរបស់អង្គជំនុំជម្រះ ស្តីពីៈ "ការឆ្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងផ្នែកខ្លះនៃឯកសារលេខ E114, E114/1, E131/1/0, E131/6, E136 និងលេខ E158", ចុះថ្ងៃទី៣១ មករា ២០១២, កថាខណ្ឌទី២ ។

[24] *ដូចគ្នានឹងខាងលើកន្លែងដដែល,* ត្រង់កថាខណ្ឌទី៧។

"បទដ្ឋានអប្បបរមា ស្តីពីភាពជាប់ពាក់ព័ន្ធ និងភាពអាចឲ្យជឿទុកចិត្តបាន"[25]។ នៅក្នុងការបំពេញឲ្យបានតាមបទដ្ឋានស្តីពីភាពអាចជឿទុកចិត្តបាន *ដោយគ្រាន់តែឃើញមួយក្រឡេកភ្នែកដំបូង* មានកត្តាជាច្រើនណាស់ដែលត្រូវធ្វើការគិតគូរពិចារណាឲ្យបានស្របទៅតាមកាលៈទេសៈជាពិសេសណាមួយទៅតាមករណីនីមួយៗ[26]។ ក្នុងនាមជាផ្នែករួមផ្សំដែលពាក់ព័ន្ធមួយទៅនឹងភាពអាចឲ្យជឿទុកចិត្តបាន ហើយដែលមានការទាក់ទងគ្នានឹងចម្លើយតបបច្ចុប្បន្ននេះ សហព្រះរាជអាជ្ញា ក៏បានសង្កត់ធ្ងន់ផងដែរ អំពីភាពចាំបាច់ត្រូវបង្ហាញឲ្យឃើញថា យថាភាពនៃឯកសារភស្តុតាង បំពេញបានទៅតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋានស្តីពី *គ្រាន់តែឃើញមួយក្រឡេកភ្នែកដំបូង*។

១៤- ក្នុងពេលនេះ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់លាស់អំពីជំហររបស់ សហព្រះរាជអាជ្ញា ថា ការធ្វើតេស្តសាកល្បងពិសោធន៍អំពីភាពអាចទទួលយកបាន គឺគ្រាន់តម្រូវឲ្យបំពេញឲ្យបានតាមបទដ្ឋានស្តីពី *គ្រាន់តែឃើញមួយក្រឡេកភ្នែកដំបូង* ប៉ុណ្ណោះ។ ហេតុដូចនេះ អង្គជំនុំជម្រះ ក៏បានបញ្ជាក់ផងដែរអំពីជំហរដែលបានប្រកាន់យកតាំងពីយូរមកហើយរបស់ សហព្រះរាជអាជ្ញា ដែលថា "មិនមានលក្ខខណ្ឌតម្រូវឲ្យយថាភាពនៃឯកសារណាមួយ ត្រូវតែបង្ហាញឲ្យឃើញភស្តុតាងជាស្ថាពរនោះឡើយ នៅក្នុងដំណាក់កាលនេះ"[27]។

## IV. **អំណះអំណាង**

### *i. អំពីតេស្តសាកល្បងពិសោធន៍ដែលត្រូវយកមកប្រើមានលក្ខណៈតឹងតែងពេក*

១៥- ដូចបានធ្វើការកត់សំគាល់ជូនរួចមកហើយ ដោយ កសព នៅក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់ឆ្លើយតបទៅនឹងសំណើដើមរបស់មេធាវីការពារក្តី ការសួរដេញដោលដ៏ទូលំទូលាយអំពីឯកសារនេះគឺ វាមិនស្របតាមបទដ្ឋានស្តីពីភាពអាចទទួលយកបាន *ដោយគ្រាន់តែឃើញមួយក្រឡេកភ្នែកដំបូង* ដូចដែលមានចែងនៅក្នុងអនុស្សរណៈនោះទេ[28]។ សារណានានារបស់មេធាវីការពារក្តីឲ្យដឹងថា ភាគីដែលស្នើសុំត្រូវតែកំណត់ឲ្យបានប្រាកដនូវខ្សែសង្វាក់នៃការគ្រប់គ្រងឯកសារ នៅមុនពេលមានការធ្វើតេស្ត

---

[25] ឯកសារលេខ **E131/19**, ចម្លើយតបរួមរបស់ សហព្រះរាជអាជ្ញាទៅនឹងការជំទាស់នានាចំពោះបញ្ជីឯកសារសំរាប់សវនាការលើកដំបូង, ចុះថ្ងៃទី១ ធ្នូ ២០១២, កថាខណ្ឌទី៥៧។

[26] ឯកសារលេខ **E114/1**, ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "ការជំទាស់របស់ អៀង សារី ចំពោះភាពអាចទទួលយកបាននៃប្រភេទឯកសារមួយចំនួន", ចុះថ្ងៃទី១៦ កញ្ញា ២០១១, កថាខណ្ឌទី១០។

[27] ឯកសារលេខ **E131/19**, ចម្លើយតបរួមរបស់ សហព្រះរាជអាជ្ញាទៅនឹងការជំទាស់នានាចំពោះបញ្ជីឯកសារសំរាប់សវនាការលើកដំបូង, ចុះថ្ងៃទី១ ធ្នូ ២០១២, កថាខណ្ឌទី៥៩ (អភន្តរសញ្ញាខាងក្នុង មិនត្រូវបានដាក់បញ្ចូល) ។

[28] ឯកសារលេខ **E1/39.1** ត្រង់ទំព័រ៨៥ : កថាខណ្ឌពីទី១ដល់ទី២២។

សាកល្បងអំពីយថាភាពនៃឯកសារ។ ការពិត គ្មានសញ្ញាសំគាល់អំពីភាពអាចជឿទុកចិត្តបានណាមួយ ដែលមានលក្ខណៈជាការកំណត់សម្រេចចំពោះការសាកល្បងដូច្នោះទេ ហើយក៏គ្មាននរណាម្នាក់ដែលតម្រូវឱ្យកំណត់ឱ្យហួសពី *បទដ្ឋានឃើញមួយក្រឡែកភ្នែក* នៅដំណាក់កាលនៃការទទួលយក ក្នុងពេលនៃការសួរដេញដោលនេះដែរ។

១៦- សំណើរបស់មេធាវីការពារក្តី គឺជាការដាក់ឯកសារចុងក្រោយបំផុតចំនួនមួយឈុត ដែលមានភាពផ្ទុយគ្នា ទាក់ទងអំពីបទដ្ឋានដែលត្រូវយកមកអនុវត្តនៅក្នុងការវាយតម្លៃអំពីយថាភាពនៃឯកសារនានា។ ក្នុងខែមករា ឆ្នាំនេះ មេធាវីការពារក្តីបានប្រកាន់ជំហរថា ឯកសារទាំងឡាយអាចនឹងទទួលយកបាន លុះត្រាតែឯកសារទាំងនោះ "បំពេញបានទៅតាមការធ្វើតេស្តសាកល្បងអំពីភាពអាចទទួលយកបាន *ដោយគ្រាន់តែឃើញមួយក្រឡេកភ្នែកដំបូង*"[29]។ តាមមេធាវីការពារក្តី " ចរិតលក្ខណៈខាងក្នុង" និង "លក្ខណៈពិសេសខាងក្រៅ" នៃឯកសារនានាដែលខ្លួនបានដាក់សំណើសុំជាផ្លូវការ នឹងស្នើសុំឱ្យមានភាពអាចជឿទុកចិត្តបាន ដោយគ្រាន់តែឃើញមួយក្រឡេកភ្នែកនេះ[30]។ មុនការដាក់បញ្ចូលទៅក្នុងសំណុំរឿង នូវឯកសារណាមួយក៏អាចនឹងប្រើធ្វើជាសញ្ញាសំគាល់មួយអំពីភាពអាចឱ្យជឿទុកចិត្តបានដែរ នៅក្នុងការប៉ាន់ស្មានថ្មីៗនេះរបស់មេធាវីការពារក្តី[31]។ នៅពេលនេះ ខ្សែសង្វាក់នៃការថែរក្សាគ្រប់គ្រងឯកសារ សំរាប់ធ្វើជាកត្តាកំណត់សំរេចនៅក្នុងការធ្វើតេស្តសាកល្បង និងបទដ្ឋានដ៏ខ្ពស់នៃភស្តុតាងដែលមេធាវីការពារ ដែលកំពុងតែតស៊ូមតិនៅក្នុងសារណារបស់មេធាវីការពារក្តីមានភាពផ្ទុយគ្នាពីជំហរថ្មីៗរបស់មេធាវីការពារក្តី នៅក្នុងខែមករា ឆ្នាំនេះ។

១៧- តាមរយៈសំណើរបស់មេធាវីការពារក្តីនេះ មេធាវីការពារក្តីបានព្យាយាមនាំមកនូវវិធីសាស្ត្រមួយនៃការធ្វើតេស្តសាកល្បងអំពីភាពអាចទទួលយកបាននៃឯកសារ ដែលកាន់តែតឹងរឹងជាងវិធីសាស្ត្រដែលកំពុងអនុវត្តនៅ អវតក ទៅទៀត។ អំណះអំណាងនៅក្នុងសារណារបស់មេធាវីការពារក្តីដែលថា សារៈសំខាន់នៃព័ត៌មាន ដែលស្នើសុំដែលទាក់ទងនឹងខ្សែសង្វាក់នៃការថែរក្សាគ្រប់គ្រងឯកសារ "មិនអាចត្រូវបានធ្វើការសង្កត់ធ្ងន់ហួសពេក" ដែលស្នើឱ្យមានលក្ខខណ្ឌតម្រូវមួយថា ខ្សែសង្វាក់នៃការថែរក្សាគ្រប់គ្រងឯកសារត្រូវតែបង្ហាញភស្តុតាង ឬបញ្ជាក់ការពិត សូម្បីតែថាម្យ៉ាងទៀតប្រសិនជាយថាភាពនៃឯកសារនានា មិនមានភាពគួរឱ្យមន្ទិលសង្ស័យ ហើយសញ្ញាបង្ហាញខ្លាំងផ្សេងទៀតសំរាប់ជួយគាំទ្រដល់យថាភាព ត្រូវបានបង្ហាញការពិតថា ស្របតាមបទដ្ឋានត្រឹមត្រូវនោះក៏ដោយ។

---

[29] ឯកសារលេខ **E131/1/13**, បញ្ជីឯកសាររបស់ នួន ជា ដែលត្រូវដាក់ចំពោះមុខអង្គជំនុំជម្រះនៅក្នុងសវនាការតូចលើកដំបូង,ចុះថ្ងៃទី៣១ មករា ២០១២, កថាខណ្ឌទី២។

[30] *ដូចគ្នានឹងខាងលើកន្លែងដដែល*, ត្រង់កថាខណ្ឌទី៤។

[31] *ដូចគ្នានឹងខាងលើកន្លែងដដែល*។

១៨- ការធ្វើតេស្តសាកល្បងអំពីភាពអាចទទួលយកបាននៃឯកសារដែលទាក់ទងនឹងកត្តាទាំងបីដូចដែលបាន បញ្ជាក់នៅក្នុងវិធាន៨៧(៣)នៃវិធានផ្ទៃក្នុង និងការធ្វើតេស្តសាកល្បងដែលបានប្រកាសឲ្យដឹងជាលាយលក្ខណ៍អក្សរដោយអង្គជំនុំជម្រះ គឺជាបរិបទដ៏ជាក់លាក់ និងដែលពឹងផ្អែកលើការគួបផ្សំបញ្ចូលគ្នានៃសញ្ញាបង្ហាញនានាដែលមានស្រាប់។ ដូចដែលបានវែកញែកបង្ហាញជូនដោយ សហព្រះរាជអាជ្ញា នៅក្នុងសេចក្តីសន្និដ្ឋានមុនៗ និងការទាញសេចក្តីសន្និដ្ឋានប្រកបដោយតក្កភាពពីការសំរេចរបស់អង្គជំនុំជម្រះនោះ ភស្តុតាងដូចជា ខ្សែសង្វាក់នៃការថែរក្សាគ្រប់គ្រងរបស់ឯកសារ គឺជាសញ្ញាសំគាល់ហើយ ក៏ប៉ុន្តែគឺមានតែមួយក្នុងចំណោម អ្វីៗដែលអាចសញ្ញាសំគាល់ដទៃទៀតជាច្រើនអំពីយថាភាព។

១៩- មេធាវីការពារក្តីធ្លាប់បានយល់ព្រមរួចហើយ ទៅនឹងការអនុវត្តវិធីសាស្ត្របត់បែននេះចំពោះភាពអាចទទួលយកបាន ដូចដែលច្បាប់អន្តរជាតិ និងច្បាប់កម្ពុជាបានណែនាំដូច្នោះដែរ ថាវាជាការមួយដែលសមស្របនៅ អ.វ.ត.ក។ នៅក្នុងការស្នើដោយផ្ទាល់មាត់កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ ដែលមេធាវីការពារក្តីបានទទួលយកតាមអង្គជំនុំជម្រះ គឺនៅក្នុង “ជំហរជាក់លាក់មួយ ទាក់ទងទៅនឹងគោលនយោបាយក្នុងការទទួលយកឯកសារយកមកធ្វើការវាយតម្លៃ”[32] ហើយបានបន្តរៀបរាប់ពីបទដ្ឋានដែលអាចអនុវត្តបាន ដូចតទៅ៖

*1 ............................................................................។ ទីមួយ ទាក់ទងទៅនឹងច្បាប់*
*2 ដែលយកមកអនុវត្តបាន គឺខ្ញុំចាប់តាំងពីអំពីដើមដំបូងនៃការកកើត អ.វ.ត.ក ហើយនិងទាក់ទងទៅនឹង*
*3 ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ពាក់ព័ន្ធទៅនឹងការទទួលយកឯកសារនេះ ដែលយើងខ្ញុំបានលើកឡើងជា*
*4 ញឹកញាប់អង្គជំនុំជម្រះមានលទ្ធភាពយ៉ាងធំធេង ក្នុងការពិនិត្យទៅលើឯកសារទាំងអស់នេះ*[33] ។

២០- ការអនុវត្តវិធីសាស្ត្របត់បែននេះចំពោះយថាភាពនៃឯកសារ គឺជាសញ្ញាសម្គាល់ ដ៏ច្រើនដែលសហព្រះរាជអាជ្ញា ធ្លាប់បានធ្វើការកំណត់ និងបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។ ចំពោះបញ្ហាជាក់លាក់នៃ ខ្សែសង្វាក់ក្នុងការគ្រប់គ្រងឯកសារ ព័ត៌មានដ៏ទូលំទូលាយ ធ្លាប់ត្រូវបានស្នើដាក់ជូនរួចហើយ រួមទាំងភ័ស្តុតាង*ផ្ទាល់មាត់* (*viva voce* evidence) ដែលបានមកពីសាក្សីពីររូបផង។ ដូច្នេះ អង្គជំនុំជម្រះធ្លាប់មានភ័ស្តុតាងដ៏ច្រើនលើសលុប នៅចំពោះមុខខ្លួនរួចហើយ ដើម្បីធ្វើការកំណត់អំពីយថាភាពនៃឯកសារ ដោយមានមូលដ្ឋាននៅលើការបូក បញ្ចូលគ្នានៃសញ្ញាបង្ហាញតាមដែលខ្លួនយល់ឃើញថាសមស្រប ដែលអាចមាន រួមទាំងភ័ស្តុតាង ស្តីពី ខ្សែសង្វាក់នៃការគ្រប់គ្រងឯកសារផង។

---

[32] **E27.1**, ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ១៦ កុម្ភៈ ២០១២, ទំព័រ 30:10-16, [ខ្មែរ៖ ទំព័រ ២២, បន្ទាត់ ១-៤]។

[33] *ដដែលដូចមុន* ត្រង់ទំព័រ 30:10-16។

២១- បទដ្ឋានដ៏ខ្ពស់នៃសក្ខីកម្មដែលបានស្នើសុំដាក់នៅក្នុងសារណាមេធាវីការពារក្ដី ពាក់ព័ន្ធទៅនឹងខ្សែសង្វាក់នៃការគ្រប់គ្រងឯកសារ ក៏មានលក្ខណៈផ្ទុយគ្នាផងដែរ ទាំងទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ និងទាំងទៅនឹងសម្បទានពីមុនៗដែលមេធាវីការពារក្ដីបានធ្វើទៅលើគោលជំហរនេះ។ បទដ្ឋាន *មួយក្រឡេកភ្នែក* ដែលអាចអនុវត្តបាននៅដំណាក់កាលនៃភាពអាចទទួលយកបាន ពុំតម្រូវឲ្យមាន បទប្បញ្ញត្តិដ៏ស៊ីជម្រៅ និងយ៉ាងទូលំទូលាយ ស្ដីពីព័ត៌មានដែលមេធាវីការពារក្ដីបានស្នើឡើង នោះឡើយ ជាពិសេស ពាក់ព័ន្ធទៅនឹងភស្តុតាង និងការវិភាគដ៏សំខាន់ ដែលបានផ្ដល់ជូនរួចហើយ។ ដោយសារពុំមានលក្ខខណ្ឌតម្រូវដែលថា សមាសភាគណាមួយក៏ដោយនៃពិសោធន៍ស្ដីពីភាពអាចទទួលយកបាន ត្រូវតែបានបង្កើតឡើងឲ្យហួសពីបទដ្ឋាន*មួយក្រឡេកភ្នែក* នោះ សារណារបស់មេធាវីការពារក្ដីគឺនៅខ្វះមូលដ្ឋានតាមផ្លូវច្បាប់។ ក្នុងឋានៈជាភាគីដែលបានស្នើដាក់ជូន សហព្រះរាជអាជ្ញា ធ្លាប់បានធ្វើត្រូវទៅតាមបន្ទុកតាមផ្លូវច្បាប់របស់ខ្លួនរួចហើយ ពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាននៃឯកសារ។ បទប្បញ្ញត្តិស្ដីពីតួនៃព័ត៌មានយ៉ាងពាសពេញបែបនេះ គឺមុខជានឹងពន្យារកិច្ចដំណើរការនីតិវិធី និងលើសពីតម្រូវការរបស់អង្គជំនុំជម្រះ។

*ii. ពុំមានឧបសគ្គជាក់លាក់ចំពោះឯកសារទេ*

២២- ក្នុងចំណោមកំណត់សម្គាល់ជាក់លាក់ ហើយដោយមានភាពផ្ទុយគ្នាយ៉ាងច្បាស់ជាមួយនឹងការដាក់ឯកសារបច្ចុប្បន្ននេះ មេធាវីការពារក្ដី ក្នុងពេលថ្មីៗនេះបានព្រមទទួលថា ឯកសារនានាពីប័ណ្ណសារ DC-Cam គឺដល់កំណត់តាមការព្រមតាម យ៉ាងជាក់លាក់ ពាក់ព័ន្ធទៅនឹងភាពអាចជឿជាក់បាន[34]។ នៅក្នុងការឆ្លើយតបទៅនឹងការជំទាស់របស់ ក.ស.ព ក្នុងអំឡុងពេលនៃការសួរដេញដោលលោក ឆាំង យុ មេធាវីការពារក្ដីបានបញ្ជាក់ថា ពួកខ្លួនមិនបានលើកស្នើឡើងថា មានឯកសារណាមួយដែលមានប្រភពមកពី DC-Cam ត្រូវបានក្លែងបន្លំនោះទេ[35]។ ការណ៍នេះគឺផ្ទុះបញ្ចាំងពីសញ្ញាបង្ហាញជាច្រើនអំពីយថាភាពដែល ក.ស.ព ធ្លាប់បានធ្វើការកំណត់អត្តសញ្ញាណរួចហើយពាក់ព័ន្ធទៅនឹងឯកសាររបស់ DC-Cam រួមទាំងភស្តុតាង*ផ្ទាល់មាត់* (*viva voce* evidence) ជាច្រើន ដែលមាននៅក្នុងខ្សែសង្វាក់នៃការគ្រប់គ្រង និងប្រភពដើមនៃឯកសាររបស់ពួកគាត់ផងដែរ។ ដោយពុំមានមូលហេតុជាមូលដ្ឋានណាមួយ ដែលចោទជាបញ្ហាទៅនឹងយថាភាពនៃឯកសារជាក់លាក់នោះ សំណើដ៏ទូលំទូលាយបន្ថែមទៀតដែល មេធាវីការពារក្ដីបានលើកឡើងនោះ គឺមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឡើយ។

[34] **E131/1/13** ត្រង់កថាខណ្ឌទី ៩។

[35] **E1/38.1**, ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ២ កុម្ភៈ ២០១២, ទំព័រ 88:18-20។

២៣- មេធាវីការពារក្ដីខកខានមិនបានចង្អុលបង្ហាញអំពីកង្វល់ជាក់លាក់ណាមួយទេ ឬមិនបានធ្វើការកំណត់អត្តសញ្ញាណ សូម្បីតែក្រុមឯកសារដ៏តូចណាមួយ ដែលចំណុចចាប់ផ្ដើមចូលដ៏តឹងរ៉ឹងនៃសំណើ (their stringent threshold of inquiry) របស់ខ្លួនដែលត្រូវអនុវត្តនោះឡើយ។ នៅក្នុងអំឡុងពេលនៃការលើកស្នើឡើងដោយផ្ទាល់មាត់ស្ដីពីភាពអាចទទួលយកបាន មេធាវីការពារក្ដី ពិតជាបានស្នើឡើងថា បទដ្ឋានដ៏ខ្ពស់មួយត្រូវតែយកមកអនុវត្តនៅក្នុងការកំណត់អំពីយថាភាពនៃ ភ័ស្តុតាងដែលទាក់ទងទៅនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ។ ខណៈដែល ក.ស.ព បដិសេធ ការដាក់ឯកសារដែលមានការផ្លាស់ប្តូរ ស្ដីពីពិសោធន៍លើភាពអាចទទួលយកបាន គេបានកត់សម្គាល់ ថា មេធាវីការពារក្ដីមិនបានធ្វើកិច្ចប្រឹងប្រែងណាមួយ ដើម្បីកំណត់អត្តសញ្ញាណឯកសារណាទេ សូម្បីតែឯកសារទាំងឡាយនោះ ដែលខ្លួនបានយល់ឃើញថាត្រូវស្ថិតនៅក្នុងប្រភេទនោះដើម្បីឲ្យមាន យុត្តិកម្មទៅតាមបទដ្ឋានមួយដែលខ្ពស់ជាងនេះដែលខ្លួនបានឲ្យយោបល់នោះក៏ដោយ។

២៤- មេធាវីការពារក្ដីក៏បានយល់ព្រមទទួលផងដែរ នៅក្នុងអំឡុងពេលនៃសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ថា កាលណាគេតម្រូវឲ្យមានសញ្ញាសម្គាល់បន្ថែមទៀតទៅលើយថាភាពនៃឯកសារនោះ ជនជាប់ចោទជាដំបូងត្រូវតែរៀបចំនូវការជជែកមួយ (ដោយសន្មតថាមានហេតុផល) ទៅនឹងឯកសារ ពាក់ព័ន្ធជាមុន។ សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីមានដូចតទៅ ៖

> *4 ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ក៏ប៉ុន្តែនៅពេលដែលជនជាប់ចោទ ជាពិសេស*
> *5 នៅក្នុងតុលាការនៅក្នុងសវនាការនេះតែម្តង ប្រសិនណាជាជនជាប់ចោទជំទាស់ទៅនឹងយថាភាពនៃ*
> *6 ឯកសារណាមួយនោះ យើងខ្ញុំសូមយល់ឃើញថា គឺនោះសហព្រះរាជអាជ្ញា ដែលមានបន្ទុកត្រូវបង្ហាញ*
> *7 អំពីប្រភពនៃឯកសារនេះ ជាភាសាទាក់ទងទៅនឹងការទាមទារឲ្យបង្ហាញនូវឯកសារដើម[36] ។*

២៥- មិនមានការប៉ុនប៉ងណាមួយត្រូវបានគេធ្វើឡើងដើម្បីរៀបចំនូវការជជែកមួយបែបនេះ ទៅនឹងឯកសារជាក់លាក់ណាមួយនោះឡើយ ទោះបីពេលនេះ មេធាវីការពារក្ដីស្នើសុំនូវ "សញ្ញាសម្គាល់បន្ថែម" ដ៏សំខាន់ថែមទៀតអំពីយថាភាពពាក់ព័ន្ធទៅនឹងតួឯកសារដ៏ច្រើនយ៉ាងណាក៏ដោយ។

---

[36] **E27.1**, ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ១៦ មករា ២០១២, ទំព័រ 36:8-13, [ខ្មែរ៖ ទំព័រ ២៥, បន្ទាត់ ៤-៧]

២៦- ជាងនេះទៀត ការអះអាងរបស់មេធាវីការពារក្តីដែលថា សម្ភារៈដែលបានស្នើឡើងនោះអាចនាំឲ្យមាន "លទ្ធផលដោះបន្ទុក" នោះ គឺមិនសមហេតុផលទេ។ ការណ៍ដែលគ្រាន់តែអវត្តមាននៃភស្តុតាងនោះ មិនអាចជាការដោះបន្ទុកបានឡើយ។ បើសិនជាយថាភូតរបស់ឯកសារមួយ ត្រូវបានកំណត់ឡើងតាមសញ្ញាបង្ហាញដទៃទៀតយ៉ាងត្រឹមត្រូវ អវត្តមាននៃភស្តុតាងបន្ថែមអំពីខ្សែសង្វាក់នៃការគ្រប់គ្រងឯកសាររបស់វា មិនបានដោះបន្ទុកជនជាប់ចោទ ឬធ្វើឲ្យខូចតម្លៃនៃភាពជឿជាក់ចំពោះភស្តុតាងឯកសារនៅក្នុងសំណុំរឿងឡើយ។ លើសពីនេះ សហព្រះរាជអាជ្ញាកត់សំគាល់ឃើញថា ខ្លឹមសារនៃព័ត៌មានដ៏ច្រើនទាក់ទងនឹងខ្សែសង្វាក់នៃការគ្រប់គ្រងសម្ភារៈឯកសាររបស់ DC-Cam ត្រូវបានលើកហេតុផល និងបានបានដាក់រួចហើយទៅក្នុងសំណុំរឿង។ ក្នុងកាលៈទេសៈទាំងនេះ គេមិនច្បាស់ថាតើហៀលទិន្នន័យដែលបានស្នើនោះ នឹងនាំមកនូវព័ត៌មានថ្មីណាមួយដែលនឹងបានជាជំនួយដល់អង្គជំនុំជម្រះ ឬភាគីដទៃទៀតនោះទេ។

## V. សំណើ

២៧- សំណើរបស់មេធាវីការពារក្តី បានធ្វើឡើងនៅដំណាក់កាលចុងក្រោយដ៏មិនសមហេតុផលមួយនៃកិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធនឹងការទាមទារព័ត៌មានដ៏ទូលំទូលាយដែលមិនអាចធ្វើយុត្តិកម្មបាន ដែលថាបើសិនជាគេអនុញ្ញាតឲ្យធ្វើដូច្នោះនោះ មុខជានឹងមានហានិភ័យ នូវសំណើស្រដៀងគ្នានានាសម្រាប់ព័ត៌មានយ៉ាងច្រើនលើសលុបបហួសពីតម្រូវការរបស់អង្គជំនុំជម្រះ។ ដូច្នេះ សំណើនេះបណ្តាលឲ្យមានហានិភ័យមួយនៃការពន្យារពេលដែលមិនចាំបាច់ ចំពោះកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន និងមិនមានយុត្តិកម្មផ្លូវច្បាប់ផងដែរ។ ដូច្នេះ សហព្រះរាជអាជ្ញា សូមស្នើថា សំណើរបស់មេធាវីការពារក្តីគួរតែត្រូវបានបដិសេធចោល៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |